**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣*៥

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន**
**និងយុវនីតិសម្បទា**

លេខ ០១១ ស.អ.យ.

*រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៤*

# ប្រកាស

**ស្តីពី**

**ការប្រើប្រាស់រូបសញ្ញា និងតំរុយក្បាលលិខិត**
**របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

## រដ្ឋមន្ត្រីក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- ពិនិត្យឃើញការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១.-** ត្រូវបានប្រកាសឱ្យប្រើប្រាស់អក្សរកាត់ និងរូបសញ្ញា សំរាប់សំគាល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានលក្ខណៈ និងអត្ថន័យដូចខាងក្រោម:

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អក្សរកាត់ : ស.អ.យ.
- អក្សរអង់គ្លេស Ministry of Social Affairs, Veterans and Youth Rehabilitation
  អក្សរកាត់ជាភាសាអង់គ្លេស : MOSVY

- រូបសញ្ញាក្រសួង : (ឧបសម្ព័ន្ធ ១)
  - ភាគរង្វង់មូលព័ទ្ធដោយស្លឹកឈើ ជារង្វង់ស្លែងក្រប៊ី មានសមាមាត្រស្មើនឹង ៥ ភាគ លើ ៦ ភាគស្លឹកឈើព័ទ្ធស្លែងក្រប៊ី ជានិមិត្តរូប ទឹកដី ព្រៃឈើ ធនធានធម្មជាតិ និងសម្បូរបែបរបស់ព្រះរាជាណាចក្រកម្ពុជា
  - រង្វង់មូលជុំវិញខាងលើឈ្មោះក្រសួងជាភាសាខ្មែរ ខាងក្រោមឈ្មោះក្រសួងជាភាសាអង់គ្លេស ភ្ជាប់ដោយក្បាច់ពណ៌មាស តំណាងឱ្យភាពសហការយ៉ាងត្រចះត្រចង់ ក្នុងការអនុវត្តការងារ
  - ផ្ទៃក្នុងរង្វង់មូលពណ៌ផ្ទៃមេឃ តំណាងឱ្យសេរីភាព និងសន្តិភាព
  - ផែនទីព្រះរាជាណាចក្រកម្ពុជា ពណ៌បៃតងខ្ចី នៅចំកណ្តាល តំណាងឱ្យទឹកដីដ៏ស្រស់បំព្រងនៃព្រះរាជាចក្រកម្ពុជា
  - រូបមនុស្សជាក្រាហ្វិក ៣ នាក់ ពណ៌ខៀវចាស់ តំណាងវ័យកណ្តាល វ័យកុមារ វ័យចាស់ ស្ថិតនៅលើ ផែនទី ជានិមិត្តរូបនៃរូបសញ្ញាប្រជាពលរដ្ឋ ដែលនឹងទទួលនូវសេវាសង្គមកិច្ច សង្គ្រោះ ថែទាំ អភិវឌ្ឍន៍ និងសុខុមាលភាព និងជាតំណាងឱ្យភារកិច្ចស្នូលទាំង ៣ របស់ក្រសួង លើវិស័យ សង្គមកិច្ច វិស័យអតីតយុទ្ធជន និងវិស័យយុវនីតិសម្បទា
- គំរូក្បាលលិខិត (ឧបសម្ព័ន្ធ ២) ។

**ប្រការ ២.-** ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋាន សង្គមកិច្ច និងយុវនីតិសម្បទា នាយកដ្ឋាន គ្រប់មន្ទីរ ខេត្ត-ក្រុង អង្គភាពស្ថាប័នក្រោម ឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។/.

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**ចំលងជូនៈ**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទៀ បាញ់
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

(ឧបសម្ព័ន្ធ ១ លេខ ៦៦៧ អ.ស.យ.)

កំពស់ 5 ភាគ




6 ភាគ

ទទឹង

រដ្ឋមន្ត្រី

អ៊ិត សំហេង

(ឧបសម្ព័ន្ធ ២ លេខ ០១១ ស.អ.យ)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

លេខ ស.អ.យ. *រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០០*

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ. ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambobodia. Fax/Phone: (855) 23 726086

Kingdom of Cambodia
Nation Religion King
*****

Ministry of Social Affairs, Veterans
and Youth Rehabilitation
No. MOSVY

Phnom Penh, 200

Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambobodia. Fax/Phone: (855) 23 726086